ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣២.សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ និង បណ្តាប្រទេសផ្តល់ជំនួយ សម្រាប់ទ្រទ្រង់ដំណើរការអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ ២៨ សសរ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការកែសម្រួល និងកំណត់ភារកិច្ចជូន ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១:** បង្កើតក្រុមការងារសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ និងបណ្តាប្រទេសផ្តល់ជំនួយសម្រាប់ទ្រទ្រង់ដំណើរការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកប្រចាំការ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធាន

២- ឯកឧត្តម **ហេង វង្សប៊ុនឆាត** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី ជាអនុប្រធាន
៣- ឯកឧត្តម **ឱម យ៉ិនទៀង** ទេសរដ្ឋមន្ត្រី ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ជាអនុប្រធាន
៤- ឯកឧត្តម **កែវ រ៉េមី** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការ
សិទ្ធិមនុស្សកម្ពុជានៃរាជរដ្ឋាភិបាល ជាអនុប្រធានអចិន្ត្រៃយ៍
៥- ឯកឧត្តម **ច័ន្ទ តានី** រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក
៦- ឯកឧត្តម **អ៊ុច បូរិទ្ធ** រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក
៧- ឯកឧត្តម **កើត រិទ្ធ** រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ ជាសមាជិក
៨- ឯកឧត្តម **ហែម ក្រាញ់ តូនី** អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី និងជា
ប្រធានរដ្ឋបាលស្តីទី នៃ អ.វ.ត.ក ជាសមាជិក
៩- ឯកឧត្តម **ម៉ៅ ច័ន្ទតារា** អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណប័ណ្ណ និង
លិខិតឆ្លងដែន ក្រសួងមហាផ្ទៃ ជាសមាជិក
១០-ឯកឧត្តម **ឆាយ ស៊ីណារិទ្ធ** អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ
ក្រសួងមហាផ្ទៃ ជាសមាជិក

**ប្រការ២:** ក្រុមការងារខាងលើ មានបេសកកម្ម ដូចខាងក្រោម៖

- សហការ និង សហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ (អ.ស.ប.) និងបណ្តាប្រទេសផ្តល់ជំនួយ ដើម្បីធានាឲ្យ អ.វ.ត.ក. ដំណើរការទៅដោយរលូន និងទទួលបានជោគជ័យ ផ្អែកលើក្របខ័ណ្ឌច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និង កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប. ។
- ជួយកៀរគរថវិកាពី អ.ស.ប. និងពីបណ្តាប្រទេសផ្តល់ជំនួយ ដើម្បីទ្រទ្រង់ដល់ដំណើរការការងាររបស់ អ.វ.ត.ក.។
- គិតគូរអំពីការងារកេរដំណែលរបស់ អ.វ.ត.ក. រួមមានការថែរក្សាទុក និងការគ្រប់គ្រងសំណុំរឿងទាំងអស់របស់ អ.វ.ត.ក. ដើម្បីឲ្យសាធារណជន និងអ្នកស្រាវជ្រាវបានយល់ដឹងអំពីដំណើរការ និងសមិទ្ធផលរបស់ អ.វ.ត.ក. ក្នុងការទប់ស្កាត់ និងប្រឆាំងការវិលត្រលប់មកវិញនូវរបបប្រល័យពូជសាសន៍។
- ជំរុញឲ្យមានការផ្ទេរចំណេះដឹង និងជំនាញ រួមទាំងធនធានមនុស្ស និងបទពិសោធន៍អនុវត្តល្អៗដែលទទួលបានពី អ.វ.ត.ក. ទៅប្រព័ន្ធយុត្តិធម៌ជាតិ ដើម្បីកសាងសមត្ថភាព និងធ្វើឲ្យកាន់តែប្រសើរឡើងនូវសេវាយុត្តិធម៌សាធារណៈ ។

**ប្រការ៣:** ក្រុមការងារខាងលើ មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម **ហែម ក្រាញ់ តូនី** អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី និងជា
ប្រធានរដ្ឋបាលស្តីទី នៃ អ.វ.ត.ក. ជាអគ្គលេខាធិការ
២- ឯកឧត្តម **រោង ឈុង** មន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងជាប្រធានផ្នែកគ្រប់គ្រង
ធនធានមនុស្សភាគីជាតិ នៃ អ.វ.ត.ក. ជាអគ្គលេខាធិការរង
៣- ឯកឧត្តម **ថោង សុជាតិ** ប្រធានផ្នែកថវិកា និងហិរញ្ញវត្ថុភាគីជាតិ នៃ អ.វ.ត.ក. ជាអគ្គលេខាធិការរង

៤- ឯកឧត្តម **ផូច សំភី** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលតុលាការ ក្រសួងយុត្តិធម៌ ជាអគ្គលេខាធិការរង

៥- លោកជំទាវ **ហេឡឺន ចារវីស** ទីប្រឹក្សារាជរដ្ឋាភិបាល ជាសមាជិក

៦- ឯកឧត្តម **ស៊ា ម៉ៅ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

៧- ឯកឧត្តម **ម៉ិន ត្រៃឈៃ** ជំនួយការផ្ទាល់ឯកឧត្តម **ម៉ិន ឈិន** ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុក ប្រចាំការ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

**ប្រការ៤:** អគ្គលេខាធិការដ្ឋាន ជាសេនាធិការ នៃក្រុមការងារខាងលើ ដើម្បីជួយសម្រួលកិច្ចការជាប្រចាំ រួមមាន ការងារគតិយុត្តិ ការងារបច្ចេកទេស ការរៀបចំប្រជុំ ការធ្វើរបាយការណ៍ ការងារភស្តុភារ-ហិរញ្ញវត្ថុ ការងាររដ្ឋបាល និងការងារផ្សេងៗទៀតតាមការកំណត់របស់ប្រធាន។

**ប្រការ៥:** ប្រធានក្រុមការងារអាចកោះប្រជុំ និងអញ្ជើញឥស្សរជនផ្សេងទៀត ព្រមទាំងអ្នកជំនាញការជាតិ និង បរទេសដែលពាក់ព័ន្ធ មកប្រជុំពិភាក្សា និងពិគ្រោះយោបល់តាមការចាំបាច់។

**ប្រការ៦:** ប្រធានក្រុមការងារ ត្រូវធ្វើរបាយការណ៍ជាប្រចាំអំពីដំណើរការនៃក្រុមការងារ និងរាល់បញ្ហាប្រឈម ដែលត្រូវដោះស្រាយជូននាយករដ្ឋមន្ត្រី។

**ប្រការ៧:** ក្រុមការងារនេះ មានសិទ្ធិប្រើប្រាស់ទីតាំង ត្រា និងសម្ភារៈផ្សេងៗរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បី សម្រេចបេសកកម្មខាងលើ។

**ប្រការ៨:** សេចក្តីសម្រេចលេខ៥៥ សសរ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រុមការងារសហប្រតិបត្តិការ ជាមួយអ្នកជំនាញច្បាប់បរទេស ដើម្បីរៀបចំនីតិវិធីសម្រាប់កាត់ទោសឧក្រិដ្ឋជនខ្មែរក្រហម និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩:** ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងឯកឧត្តម លោកជំទាវដែលមានរាយនាមក្នុងប្រការ១ និងប្រការ៣ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី* ០៤ *ខែ* មេសា *ឆ្នាំ២០១៧*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល៖*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ